ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN

# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

លេខ ០៥ ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២



សកម្មភាពរៀបចំដឹកជញ្ជូនសម្ភារឯកសារបោះឆ្នោតទៅ គធ/ខប ទាំង ២៤

## មាតិកា


- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវនៃភ្នាក់ងារសន្តិសុខបោះ....... ២
- គ.ជ.ប ផ្សព្វផ្សាយអំពីបទបញ្ញា និងនីតិវិធីនៃការឃោសនា......... ៤
- ផ្នែកកស្តុការត្រៀមបញ្ជូនសម្ភារបោះឆ្នោតនៅក្នុងដំណាក់កាល. ៧
- គោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធី........ ៩
- គោលការណ៍សម្រាប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ក្នុងការលក់.......... ១១
- គោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធ..... ១៣




www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវ នៃភ្នាក់ងារសន្តិសុខបោះឆ្នោត



សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងដែលត្រូវបានចាត់តាំងឲ្យបំពេញភារកិច្ចការពារសន្តិសុខ សម្រាប់ការបោះឆ្នោត ហៅកាត់ **"ភ្នាក់ងារសន្តិសុខបោះឆ្នោត"** ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវផ្អែកលើច្បាប់ពិសេសច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ញា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) សម្រាប់ការបោះឆ្នោត យកមកធ្វើជាមូលដ្ឋានសំខាន់ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។

តាមខ្លឹមសារនៃសៀវភៅក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវចូលរួមការពារសុវត្ថិភាព ក្នុងដំណើរការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការការពារសម្ភារ ឧបករណ៍សម្រាប់ដំណើរការបោះឆ្នោតទាំងមូល ។

ក្នុងដំណើរការបោះឆ្នោតនៅថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិនីមួយៗ សមាជិកនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងដល់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឡើយ ។ សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចងចាំថា ៖

- អ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលការការពារសន្តិសុខ និងសុវត្ថិភាព ដើម្បីឲ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។
- បេក្ខជន វាគ្មិន ឬឃោសនិក ភ្នាក់ងារ និងតំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាព ក្នុងគ្រប់សកម្មភាពស្របច្បាប់ ។

ដូច្នេះ ភ្នាក់ងារសន្តិសុខបោះឆ្នោត មានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដូចជា ៖

១. ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ។

២. ត្រូវរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ក្នុងពេលបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ។

៣. ត្រូវធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នា ក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។





កិច្ចប្រជុំផ្សព្វផ្សាយកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ឆ្នាំ២០១១-២០១៤ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១

៤. ត្រូវចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ ។

៥. នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខចំនួន ៣នាក់ ដើម្បីការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវមានឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខចេញដោយ គ.ជ.ប ។

៦. ត្រូវយាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតយ៉ាងតឹងរ៉ឹងបំផុត ។

៧. មិនត្រូវអនុញ្ញាតឲ្យជនណាម្នាក់ដែលមានអាវុធ ឬមានលាក់អាវុធនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែសមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬកងនគរបាលជាតិ ដែលមានភារកិច្ច និងត្រូវបានស្នើសុំដោយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ដើម្បីដោះស្រាយបាតុភាពដែលអាចនឹងកើតមាន ។

៨. ត្រូវស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ច ក្នុងករណីមានសំណូមពរពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងគោលបំណងស្នើសុំឲ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ ។

៩. ត្រូវបានស្នើឲ្យជួយការពារការដឹកជញ្ជូនសម្ភារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតពីគោលដៅមួយទៅកាន់គោលដៅមួយតាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១០. មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល ។

១១. មេបញ្ជាការកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការការពារនូវសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៕

# គ.ជ.ប ផ្សព្វផ្សាយអំពីបទបញ្ញា និងនីតិវិធីនៃការឃោសនាបោះឆ្នោត

ដើម្បីឲ្យការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ប្រព្រឹត្តទៅដោយរលូនស្របតាមច្បាប់បោះឆ្នោត បទបញ្ញា និងនីតិវិធីនោះ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានរៀបចំកិច្ចប្រជុំមួយ ដោយអញ្ជើញតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួម និងបានផ្សព្វផ្សាយណែនាំអំពីនីតិវិធី និងការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។





សន្និសីទសារព័ត៌មានកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំបានមានប្រសាសន៍ថា ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ជូនដល់អ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៥ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ ហើយសកម្មភាពត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។

ឯកឧត្តម ឯម សូផាត បានបន្តថា នៅក្នុងការឃោសនាបោះឆ្នោត ក៏មានសកម្មភាពមួយចំនួនដែលត្រូវហាមឃាត់រួមមាន ៖

- ការធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសម្លេងឆ្នោត ។
- ការបង្ខំឱ្យស្បថឱ្យបោះឆ្នោតជូនគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- គណបក្សនយោបាយ បេក្ខជន សកម្មជន និងអ្នកគាំទ្រមិនត្រូវប្រើប្រាស់សម្ភារ ប្រាក់កាស ទិញទឹកចិត្ត អ្នកបោះឆ្នោត ។
- ចំពោះមន្ត្រីរាជការ ៖
  - ហាមប្រើប្រាស់ទីតាំងរដ្ឋ ឬអាគារ ការិយាល័យរបស់រដ្ឋ ។
  - ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ ដូចជា ៖ រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ រដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ។
  - ហាមប្រើប្រាស់ឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬដោយចំពោះទៅលើដំណើរការបោះឆ្នោត ។
  - ហាមប្រើប្រាស់ពេលវេលាការងារ លើកលែងតែថ្ងៃឈប់សម្រាក ឬចប់ម៉ោងការងារ ឬក្រៅ

ម៉ោងការងារ ឬស្ថិតនៅក្នុងច្បាប់ឈប់សម្រាក។

- ចំពោះអង្គការក្រៅរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- អង្គការក្រៅរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវផ្តួចផ្តើម ឬចូលរួមក្នុងសកម្មភាពឃោសនារបស់គណបក្សនយោបាយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។
- ហាមជនបរទេសដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពឃោសនាបោះឆ្នោត។
- រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងទៅនឹងដំណើរការបោះឆ្នោត ត្រូវបញ្ឈប់ ៥ថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។
- រាល់សកម្មភាពឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ក្នុងរយៈពេល ២៤ម៉ោងមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត (ហាមធ្វើការឃោសនាថ្ងៃទី០២ និងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២) ។

ឯកឧត្តមបានបញ្ជាក់ថា គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រ ឬជនណាក៏ដោយដែលប្រព្រឹត្តល្មើសនឹងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ត្រូវមានទោសតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។

តាមខ្លឹមសារនៃសៀវភៅក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ត្រូវបានហាមឃាត់នូវសកម្មភាពដូចតទៅ ៖

១. សមាជិកនៃកងយោធពលខេមរភូមិន្ទកងរាជអាវុធហត្ថ និងកងនគរបាលជាតិ មិនត្រូវចូលរួមសកម្មក្នុងគ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយឡើយ ។ ការចូលរួមសកម្មត្រូវបានកំណត់ដូចតទៅ ៖

១.១ ការធ្វើជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ វាគ្មិន ឬក្រុមអ្នកឃោសនាបោះឆ្នោតនៃគណបក្សនយោបាយ ។

១.២ ការចូលរួមក្នុងក្បួនដង្ហែ ការជួបប្រជុំ និងក្បួនព្យុហយាត្រាដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬនឹងបេក្ខជនណាម្នាក់ ។

១.៣ ការដាក់តាំងរូបភាពផ្សាយឬឯកសារផ្សេងៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់នៅតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងរបស់អង្គភាព ។

១.៤ ការស្ទង់មតិសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៥ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៦ ការធ្វើសកម្មភាពចែកចាយសម្ភារដល់អ្នកបោះឆ្នោត ក្នុងគោលដៅគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៧ ការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈក្នុងការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៨ ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងការច្រៀងចម្រៀង ឬ/និងការផ្សព្វផ្សាយសារនយោបាយផ្សេងៗតាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

២. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំង

ប្រដាប់អាវុធ ។

៣. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាណាមួយក្នុងពេលបំពេញភារកិច្ច ។

៤. មិនត្រូវដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៥. មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត។

៦. មិនត្រូវស្មៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ឬ/និងយកអាវុធ សារធាតុផ្ទុះ ឬឧបករណ៍ប្រកបដោយគ្រោះថ្នាក់តាមខ្លួនចូលក្នុងបរិវេណខាងក្រៅ និងខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឲ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលនេះឲ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀត ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៧.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានអត្ថន័យគំរាមកំហែងដល់អាយុជីវិតរាងកាយ ឬការប៉ុនប៉ងបំភ្លេចបំផ្លាញ និងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ។

៧.២ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថា ធ្វើទារុណកម្ម ។

៧.៣ ការវាយតប់បន្តិចបន្តួច ឬជួន់ជូរលើបុគ្គលណាម្នាក់ ។

៧.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

៧.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

៧.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជា៖ ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៧.៧ ការបាញ់កាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៧.៨ ការយកសាកសពសត្វជាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឲ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៧.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឲ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឲ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៧.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៧.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត ។

៨. មិនត្រូវចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែមានករណីចាំបាច់ និងមានការស្នើសុំពីប្រធាន គ.ជ.ប ប្រធាន គជ/ខប ប្រធាន គឃ/សប ឬពីប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ៕

# ផ្នែកភស្តុភារត្រៀមបញ្ជូនសម្ភារបោះឆ្នោតនៅក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

ផ្នែកភស្តុភារគឺជាផ្នែកមួយដែលមានតួនាទីដ៏សំខាន់ក្នុងការផ្គត់ផ្គង់ និងការផ្តល់ជូនរាល់សម្ភារ បរិក្ខារ ឬឯកសារដែលបម្រើឱ្យកិច្ចប្រតិបត្តិការនៃការបោះឆ្នោត។

ដើម្បីធានាដល់ការផ្គត់ផ្គង់ និងបែងចែកនូវរាល់សម្ភារបរិក្ខារ និងឯកសារនានាសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឱ្យបានទាន់ពេលវេលានោះ ផ្នែកភស្តុភារបានកសាងនូវគម្រោងផែនការ និងកម្មវិធីការងារស្របតាមប្រតិទិននៃការបោះឆ្នោត និងចាត់ចែងអនុវត្តយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់។



លោក ឡៅ ឡាក់ អនុប្រធាននាយកដ្ឋានប្រតិបត្តិការ ទទួលបន្ទុកផ្នែកភស្តុភារ

ទាក់ទងនឹងការងារនេះ លោក ឡៅ ឡាក់ អនុប្រធាននាយកដ្ឋានប្រតិបត្តិការទទួលបន្ទុកផ្នែកភស្តុភារ បានផ្តល់បទសម្ភាសន៍ដល់ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ដែលមានខ្លឹមសារដូចខាងក្រោម ៖

***សំណួរ: តើការវេចខ្ចប់សម្ភារបោះឆ្នោតចាប់ផ្តើមនៅពេលណា ?***

**ចម្លើយ:** ការវេចខ្ចប់សម្ភារឯកសារក្នុងដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោតបានចាប់ដំណើរការពីថ្ងៃទី១ ខែមេសា និងបានបញ្ចប់នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២នេះ ដោយសម្រេចបាន ៖

១. កេសបណ្តុះបណ្តាលចំនួន ១.៨៦៤កេស ដែលមានសម្ភារឯកសារចំនួន ៣៦មុខ។
២. កេសគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ/ខប) ចំនួន ២០០កេស មានសម្ភារឯកសារចំនួន ៣៧មុខ។
៣. កេសគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ចំនួន ១.៦៣៣កេស មានសម្ភារឯកសារចំនួន ២៥មុខ។
៤. កេសគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត(គកប/គករ) ចំនួន ១៨.១០៧កេស មានសម្ភារឯកសារចំនួន ៤១មុខ។

***សំណួរ: សម្ភារទាំងនេះដឹកចេញទៅ គជ/ខប នៅពេលណា ?***

**ចម្លើយ:** តាមការសម្រេចរបស់ គ.ជ.ប ការដឹកជញ្ជូនសម្ភារឯកសារសម្រាប់ផ្គត់ផ្គង់ដល់ គជ/ខប គឃ/សប ក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០១២នេះ ដើម្បីផ្តល់លទ្ធភាពងាយស្រួលដល់ គជ/ខប មានឯកសារក្នុងដៃ ក្នុងការបើកវគ្គបណ្តុះបណ្តាល គឃ/សប ជំនួយការ គឃ/សប នៅតាមមណ្ឌលប្រមូលផ្តុំ។

***សំណួរ: តើមានបុគ្គលិក កម្មករចំនួនប៉ុន្មាននាក់ជួយក្នុងការងារវេចខ្ចប់នេះ ?***

**ចម្លើយៈ** ការិយាល័យកស្តុភារ និងឃ្លាំងមានបុគ្គលិក កម្មករចំនួន ២២នាក់ ដែលបំពេញការងារជំនាញលើការងារវេចខ្ចប់នេះ ក្នុងនោះមានកម្មករចំនួន ១៦នាក់ ដែលជាអ្នកប្រតិបត្តិការជាក់ស្តែង ។ ក្នុងយុទ្ធនាការនៃការវេចខ្ចប់ គ.ជ.ប បានអនុញ្ញាតឱ្យជ្រើសរើសកម្មករអណ្តែតចំនួន ៥០នាក់ បន្ថែមលើកម្លាំងដែលមានស្រាប់ សម្រាប់ធ្វើការក្នុងរយៈពេល ៣៥ថ្ងៃ។



សកម្មភាពរៀបចំវេចខ្ចប់សម្ភារឯកសារ

**សំណួរៈ ពាក់ព័ន្ធនឹងការវេចខ្ចប់នេះ តើមានភាពងាយស្រួល និងការលំបាកយ៉ាងដូចម្តេចដែរ ?**

**ចម្លើយៈ ភាពងាយស្រួល** ៖

១- ការផលិត និងការផ្គត់ផ្គង់សម្ភាររបស់ក្រុមហ៊ុនបានទាន់ពេលវេលា។សម្ភារចាប់ផ្តើមបញ្ចូលមកឃ្លាំងចាប់ពីថ្ងៃទី២៩ ខែមីនា និងបានបញ្ចប់នៅថ្ងៃទី២០ ខែមេសាឆ្នាំ២០១២ដែលជារយៈពេលមួយបង្កលក្ខណៈងាយស្រួលធ្វើឲ្យយើងត្រួតពិនិត្យសម្ភារ ជាពិសេស ការបំបែកដុំសម្ភារ និងរៀបចំប្រមូលផ្តុំទៅតាមផ្នែកៗ ដែលជៀសវាងនូវការភ័ន្តច្រឡំ ឬបាត់បង់ ។

២- រាល់ឯកសារទាំងនេះ យើងបានធ្វើតារាងបែងចែកលម្អិត ដែលកំណត់អំពីចំនួនច្បាស់លាស់ ដោយចែកសម្រាប់ផ្ទៀងផ្ទាត់សម្ភារឯកសារដែលមានក្នុងកេសបណ្តុះបណ្តាល កេស គជ/ខប គឃ/សប និង គកប/គករ ដែលមានសរុបរហូតដល់ ២០.៨០៤កេស ។

៣- យើងបានប្រើប្រាស់កម្លាំងសរុបទាំងអស់នៅក្នុងផ្នែកកស្តុភារ ដែលភាគច្រើនមានបទពិសោធន៍ក្នុងការវេចខ្ចប់គួបផ្សំជាមួយកម្លាំងថ្មីដែល គ.ជ.ប អនុញ្ញាតឱ្យជ្រើសរើសបន្ថែមចំនួន ៥០នាក់ ក្នុងនោះការបង្កើនការត្រួតពិនិត្យជាប្រចាំនៅពេលដំណើរការសង្វាក់ផលិតកម្មបញ្ចូលកេស ។

**ការលំបាក** ៖

យើងមានការលំបាកខ្លះដែរក្នុងការត្រួតពិនិត្យពីព្រោះ សម្ភារទាំងអស់ដូចជា កេស គជ/ខប យើងត្រូវត្រួតពិនិត្យរហូត ដល់ ២៤ដង និងកេស គឃ/សប រហូតដល់ ១.៦៣៣ដង ប្រសិនបើធ្វេសប្រហែសវានឹងមានការច្រឡំ ដូចនេះ ទាមទារការយកចិត្តទុកដាក់ខ្ពស់ និងមធ្យ័តបំផុត ។ ប៉ុន្តែទោះបីជាយ៉ាងណាយើងបានយកចិត្តទុកដាក់តាមការណែនាំរបស់ គ.ជ.ប ។ ការវេចខ្ចប់នេះសម្រេចបានមុនផែនការកំណត់ ៕


ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

**អ្នកគ្រប់គ្រង**

លោក មែ សារី

**ក្រុមនិពន្ធ**

លោក មិន ពុធជេដ្ឋាវណ្ណ   លោក សុខ លាត

លោក ទិន ករុណា

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សាវត្ថី

**អ្នកថតរូប**

លោក សាក់ បូរិន   លោក គឹម យុង

លោក រិន វុទ្ធី

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ   លោក ចាន់ វិបុល

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៣៥៥/១២ គ.ជ.ប

## គោលការណ៍
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃកម្មវិធីផ្សាយគោលនយោបាយ

- យោងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣
- យោងសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព លេខ ០៣០/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១១

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសម្រេចចេញនូវគោលការណ៍ស្ដីពីការរៀបចំកម្មវិធីផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ឆ្នាំ ២០១២ ដូចខាងក្រោម ។

### I- គោលបំណង

គ.ជ.ប បានរៀបចំគោលការណ៍នេះឡើងក្នុងគោលបំណងលើកកម្ពស់ដល់ការធ្វើសកម្មភាពនៃការឃោសនារបស់គណបក្សដែលបានចុះបញ្ជីបេក្ខជនផ្លូវការ ឱ្យមានឱកាសថ្លែងនូវគោលនយោបាយរួម និងកម្មវិធីនយោបាយរបស់ខ្លួន ជូនដល់ប្រជាពលរដ្ឋក្នុងការឃោសនាស្វែងរកសម្លេងឆ្នោតគាំទ្រនាពេលបោះឆ្នោត ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១២ខាងមុខ ហើយដែលត្រូវបានផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ទូរទស្សន៍ និងវិទ្យុរបស់រដ្ឋ ។

### II- ប្រធានបទសម្រាប់កម្មវិធីផ្សាយគោលនយោបាយ

ដោយផ្អែកលើភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចបានចែងនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ គ.ជ.ប បានសម្រេចផ្ដល់នូវប្រធានបទ ដូចខាងក្រោម ៖

១- ការធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ ។

២- ការផ្ដល់សេវាសាធារណៈ និងការបំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ និងការសម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមក ។

៣- ការទ្រទ្រង់សុខុមាលភាព និងលើកទឹកចិត្តឱ្យមានការបង្កើនជាសុភភាព ។

៤- ការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

៥- ការការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌បេតិកភ័ណ្ឌជាតិ។

## III- លក្ខខណ្ឌសម្រាប់កម្មវិធីផ្សាយគោលនយោបាយ

គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់ ដែលចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយគោលនយោបាយ ត្រូវតែគោរពតាមគោលការណ៍ និងលក្ខខណ្ឌដូចខាងក្រោម ៖

- ចូលរួមប្រជុំតាមការអញ្ជើញរបស់គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ដើម្បីពិភាក្សាអំពីការរៀបចំកម្មវិធីផ្សាយគោលនយោបាយគណបក្ស និងទទួលស្គាល់នូវលទ្ធផលនៃការចាប់យកលេខរៀងថត កន្លែងអង្គុយ និងម៉ោងផ្សាយរបស់គណបក្សខ្លួន ។

- យល់ព្រមទទួលយករយៈពេល ០៦ ( ប្រាំមួយ ) នាទី ក្នុងការថ្លែងនូវគោលនយោបាយរួមទៅតាមប្រធានបទនីមួយៗ សម្រាប់គណបក្សនយោបាយនីមួយៗ។

## IV- ស្ថានីយផ្សាយ

គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវធ្វើការទំនាក់ទំនងជាមួយទូរទស្សន៍ជាតិកម្ពុជា ដើម្បីរៀបចំទីកន្លែង និងវេទិកាសម្រាប់ថតកម្មវិធីផ្សាយគោលនយោបាយគណបក្សនយោបាយនេះ។

ក្រោយការថតកម្មវិធីផ្សាយគោលនយោបាយគណបក្សនយោបាយនេះរួច គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវធ្វើការទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ មានវិទ្យុ និងទូរទស្សន៍ជាតិកម្ពុជា ដើម្បីកំណត់ម៉ោង និងធ្វើការផ្សាយកម្មវិធីនេះ ជូនដល់ប្រជាពលរដ្ឋ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្ដី

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៣៧៣/១២ គ.ជ.ប

## គោលការណ៍

**សម្រាប់**

**ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយ ឲ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយ អំពីគោលនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត**

- អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជំពូកទី ៨ ស្ដីពីការឃោសនាបោះឆ្នោត ។
- អនុលោមតាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។
- អនុលោមតាមគោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ ស្ដីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

ដើម្បីឲ្យដំណើរការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសល្អ និងយុត្តិធម៌ សម្រាប់គណបក្សនយោបាយ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ដែលមានបំណងលក់ ឬជួលម៉ោងផ្សាយទៅឲ្យគណបក្សនយោបាយ ដើម្បីអនុវត្តដូចខាងក្រោម ៖

### I- សេចក្ដីប្រកាសជាសាធារណៈ

១- ស្ថានីយវិទ្យុ និងទូរទស្សន៍ ដែលមានបំណងលក់ ឬជួលម៉ោងផ្សាយ ត្រូវប្រកាសជាសាធារណៈ អំពីចំនួនម៉ោងដែលខ្លួនមានសម្រាប់លក់ ឬជួលក្នុងរយៈពេល ១ថ្ងៃ និងចំនួនម៉ោងដែលមានសម្រាប់លក់ ឬជួលក្នុងរយៈពេល ១៥ថ្ងៃ នៃដំណាក់កាលឃោសនាបោះឆ្នោត ។

២- ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈ អំពីតម្លៃដែលលក់ ឬជួលនោះ ។

៣- ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវជូនដំណឹងអំពីការលក់ ឬជួលម៉ោងផ្សាយនេះ ទៅគ្រប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ក្នុងរយៈពេលយ៉ាងតិច ១០ថ្ងៃ មុនថ្ងៃចាប់ផ្ដើមឃោសនា ។

៤- ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវផ្តល់ព័ត៌មានមក គ.ជ.ប អំពីចំនួនម៉ោងដែលមានសម្រាប់លក់ ឬជួលឲ្យគណបក្សនយោបាយ និងអំពីម៉ោងផ្សាយដែលបានលក់ ឬជួល និងឈ្មោះគណបក្សនយោបាយ ដែលបានទិញ ឬជួលម៉ោងផ្សាយ ។

## II- វិធីលក់ ឬជួលម៉ោងឲ្យគណបក្សនយោបាយ

១- ការលក់ ឬជួលម៉ោងផ្សាយឲ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយ អំពីគោលនយោបាយរបស់គណបក្សនយោបាយ ត្រូវផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ ។

២- ម្ចាស់ស្ថានីយត្រូវយកចំនួនម៉ោងសរុបដែលលក់ ឬជួល ចែកជាមួយនឹងចំនួនគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ រួចលក់តែចំណែកម៉ោងដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន ទៅឲ្យគណបក្សនយោបាយនីមួយៗ ។

៣- ក្នុងករណីមានគណបក្សនយោបាយតិច ឬតែមួយមកទិញ ឬជួលម៉ោងផ្សាយ ម្ចាស់ស្ថានីយអាចលក់ ឬជួលម៉ោងផ្សាយឲ្យគណបក្សនយោបាយដែលមានលទ្ធភាពទិញ ឬជួលនោះ នូវរយៈពេលយ៉ាងច្រើន ៣ដង នៃរយៈពេលផ្សព្វផ្សាយតាមគោលការណ៍ស្មើភាព ដូចមានចែងក្នុងចំណុចទី២ ខាងលើ ។

៤- ការលក់ ឬជួលម៉ោងផ្សាយឲ្យគណបក្សនយោបាយ មិនអនុញ្ញាតឲ្យម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍លក់ ឬជួលផ្តាច់មុខឲ្យគណបក្សនយោបាយណាមួយឡើយ ។

## III- សិទ្ធិ និងការទទួលខុសត្រូវ

១- ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ ពុំត្រូវទទួលខុសត្រូវចំពោះខ្លឹមសារ នៃការផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយឡើយ ។

២- គណបក្សនយោបាយ ត្រូវទទួលខុសត្រូវចំពោះខ្លឹមសារ នៃការឃោសនារបស់ខ្លួន ។

៣- ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ ត្រូវគោរពបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងគោលការណ៍ សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឲ្យគណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយ អំពីគោលនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

៤- ក្នុងករណី គ.ជ.ប រកឃើញថា ខ្លឹមសារនៃការឃោសនា រំលោភលើបទបញ្ញា និងនីតិវិធី របស់ គ.ជ.ប គ.ជ.ប មានសិទ្ធិស្នើឲ្យគណបក្សនយោបាយធ្វើការកែតម្រូវ ហើយប្រសិនបើនៅតែមិនព្រមកែតម្រូវ គ.ជ.ប មានសិទ្ធិដកហូត ឬបញ្ឈប់លែងឲ្យស្ថានីយនោះធ្វើការផ្សព្វផ្សាយនូវខ្លឹមសារឃោសនាទាំងស្រុង ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១២

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្ដី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៣៥៧/១៧ គ.ជ.ប

# គោលការណ៍

## សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជំពូកទី ៨ ស្តីពីការឃោសនាបោះឆ្នោត ។
- អនុលោមតាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ឬអ្នកគ្រប់គ្រងកម្មវិធី) ដែលមានបំណងរៀបចំ កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយគណបក្ស ដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដើម្បីអនុវត្តដូចខាងក្រោម ៖

### I- កិច្ចសហការជាមួយ គ.ជ.ប

#### ១- ការពិគ្រោះយោបល់

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព គ.ជ.ប មុននឹងចាប់ផ្តើមធ្វើកម្មវិធីនេះ លើបញ្ហាមួយចំនួនដូចជា ៖

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំធ្វើ ។
- ប្រធានបទ ឬសំណួរ ដែលត្រូវដាក់ជូនគណបក្សនយោបាយ ។
- ការសម្របសម្រួលទីតាំងប្រជុំ និងសន្តិសុខ សុវត្ថិភាព ។

#### ២. ការទទួលខុសត្រូវ

សាមីអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយ ដែលរៀបចំកម្មវិធីត្រូវទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយគោលនយោបាយនេះ និងត្រូវទទួលបន្ទុករាល់ការចំណាយទាំងអស់ ។

## II- កិច្ចដំណើរការកម្មវិធី

កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ។ កម្មវិធីនេះ អាចធ្វើនៅទីកន្លែងសាធារណៈ ឬឯកជន ថ្នាក់ឃុំ សង្កាត់ ថ្នាក់រាជធានី ខេត្ត និងនៅតាមស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់ ។ ដើម្បីឱ្យដំណើរការកម្មវិធីសំណួរចម្លើយ ឬពិភាក្សានេះប្រព្រឹត្តទៅមានភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយ ដែលចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ អ្នកគ្រប់គ្រងកម្មវិធីត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

### ១. ការត្រៀមរៀបចំមុនកម្មវិធីចាប់ដំណើរការ

- អ្នកគ្រប់គ្រងកម្មវិធី ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរអញ្ជើញតំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ជាផ្លូវការ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា ។
- យោងតាមកំរិតនៃការរៀបចំនៅថ្នាក់ឃុំ សង្កាត់ ឬរាជធានី ខេត្ត ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្ស ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ឬនៅក្នុងរាជធានី ខេត្តនោះ ឬគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នេះ ។
- ក្នុងករណីអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយរៀបចំកម្មវិធីនៅតាមឃុំ សង្កាត់ ឬរាជធានី ខេត្តច្រើន ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ឬរាជធានី ខេត្ត ឬនៅទូទាំងប្រទេសបានចូលរួម ។
- អ្នកគ្រប់គ្រង **កម្មវិធីសំណួរចម្លើយ ឬពិភាក្សា** ត្រូវផ្តល់ប្រធានបទ និងសំណួរ ដែលត្រូវចោទសួរក្នុងកម្មវិធីជូនគណបក្សនយោបាយយ៉ាងតិច ៧ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី ។
- ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញនោះហើយ តែពុំបានចាត់តំណាងរបស់ខ្លួនឱ្យមកចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថា គណបក្សនោះបោះបង់ចោលពេលវេលារបស់ខ្លួន ហើយកម្មវិធីនេះនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់ ។

### ២. ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅទីសាធារណៈ ឬទីកន្លែងឯកជន នៅថ្នាក់ឃុំ សង្កាត់ ឬនៅថ្នាក់រាជធានី ខេត្ត ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅនឹងស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់តែម្តង ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចអញ្ជើញប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទសំណួរបាន ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន ។

**៣. អ្នកសម្របសម្រួលកម្មវិធី**

អ្នកសម្របសម្រួល កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាព ក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព ។

**៤. ការផ្សព្វផ្សាយ កម្មវិធីសំណួរចម្លើយ ឬកម្មវិធីពិភាក្សា តាមវិទ្យុ និងទូរទស្សន៍**

កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ត្រូវអនុវត្តដូចខាងក្រោម ៖

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ដែលធ្វើនៅតាមឃុំ សង្កាត់ណា អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលមានស្ថានីយនៅក្នុងរាជធានី ខេត្ត នៃឃុំ សង្កាត់នោះ ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍នៅថ្នាក់ជាតិបាន លុះត្រាតែមានការចូលរួមគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជាផ្លូវការទាំងអស់ក្នុងរាជធានី ខេត្តណាមួយ ឬទូទាំងប្រទេស ។

**III- គោលការណ៍អនុវត្ត**

- ចំនួនម៉ោងសម្រាប់គណបក្សនយោបាយឆ្លើយសំណួរ ត្រូវផ្អែកតាមគោលការណ៍ស្មើភាព ដែលបានឯកភាពក្នុងកិច្ចប្រជុំរវាងគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព នៃ គ.ជ.ប ជាមួយគណបក្សនយោបាយ នាថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២ ។
- អ្នកគ្រប់គ្រង **កម្មវិធីសំណួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយរបស់គណបក្សត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។
- ការផ្សព្វផ្សាយ កម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយគណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោត ក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី ។
- រាល់កិច្ចដំណើរការទាំងអស់របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវគោរពច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជា និងនីតិវិធី គ.ជ.ប ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១២

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម សួស្ដី**

# សកម្មភាពចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅតាមបណ្តា រាជធានី ខេត្ត មួយចំនួន




សកម្មភាពចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសង្កាត់រលួស និងសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ




សកម្មភាពចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅឃុំរាប និងឃុំអង្គរទ្រេត ខេត្តព្រៃវែង




សកម្មភាពចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅឃុំពោធិ៍ និងឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង